# សុន្ទរកថាស្វាគមន៍ និងរបាយការណ៍

## សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងជា ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងវេទិការអន្តរសាសនាថ្នាក់ជាតិ ប្រឆាំងការជួញដូរមនុស្ស(គ.ជ.ប.ជ)

## ក្រោមប្រធានបទ៖

## « សូមកុំយកកម្ពុជា ជាគោលដៅប្រព្រឹត្តអំពើជួញដូរមនុស្ស!»

ថ្ងៃព្រហស្បតិ៍ ៤កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ត្រូវនឹងថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០២២

នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍អន្តរជាតិជ្រោយចង្វារ

- សូមក្រាបថ្វាយបង្គំ សម្ដេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី កិត្តិឧទ្ទេសបណ្ឌិត **បួរ គ្រី** សម្ដេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់!
- សូមថ្វាយបង្គំ សម្ដេចព្រះមង្គលទេព្វាចារ្យ **ឝខ្យ អានេតា** សម្ដេចព្រះសង្ឃនាយករង នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់!
- សូមថ្វាយបង្គំ សម្ដេចព្រះវនរ័ត **ណយ ច្រឹក** សម្ដេចព្រះសង្ឃនាយករងទី២ នៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់!
- សូមថ្វាយបង្គំ សម្ដេចព្រះឧត្តមវង្សា **មួង រ៉ា** សម្ដេចព្រះសង្ឃនាយករងទី៣ នៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់!
- សូមថ្វាយបង្គំ សម្ដេចព្រះពុទ្ធជ័យមុនី **ឃឹម សន** ព្រះប្រធានលេខាធិការដ្ឋានគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា និងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់!
- សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីជាទីគោរពដ៏ខ្ពង់ខ្ពស់!
- លោកឧកញ៉ា **ស្មះ កំរី** ចាងហ្វាង នៃគណៈដឹកនាំជាន់ខ្ពស់ នៃសាសនាឥស្លាមកម្ពុជា!

- លោកឧកញ៉ា **ឃួរ ម៉ាត់សា** មេដឹកនាំឥស្លាម ក្រុម កនអ៊ុម៉ាំសាន់!
- ឯកឧត្តម ព្រឹទ្ធបូជាចារ្យ **ហោង ចេង** ព្រឹទ្ធបូជាចារ្យជាន់ខ្ពស់គ្រិស្តសាសនា!
- ឯកឧត្តម **ឆែព ច័ន្ទពិសិដ្ឋ** អភិបាលព្រះសហគមន៍កាតូលិក!
- សម្តេច ឯកឧត្តម លោកជំទាវ សមាជិក ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃបណ្តាក្រសួងស្ថាប័ន!
- ឯកឧត្តម លោកជំទាវ ជាតំណាងអង្គទូត និងស្ថានតំណាងនៃបណ្តាប្រទេសជាមិត្តប្រចាំនៅព្រះរាជាណាចក្រកម្ពុជា!
- តំណាងនិកាយសាសនា យាយជី តាជី លោកគ្រូ អ្នកគ្រូ សិស្សនិស្សិត និងបងប្អូនជនរួមជាតិជាទីស្រឡាញ់រាប់អាន!

ជាបឋមក្នុងឱកាសដ៏ថ្លៃថ្លានេះ ក្នុងនាមគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើរជួញដូរមនុស្ស និងអង្គពិធីទាំងមូលសូម ខ្ញុំសម្តែងនូវគារវកិច្ចគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលសម្តេចបានឆ្លៀតឱកាសដ៏មមាញឹកនឹងមានតម្លៃអញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីវេទិកាជាតិអន្តរសាសនាប្រយុទ្ធប្រឆាំងការជួញដូរមនុស្សក្រោមប្រធានបទ «**សូមកុំយកកម្ពុជា ជាគោលដៅប្រព្រឹត្តអំពើជួញដូរមនុស្ស!**» ។

ក្នុងនាមគណៈកម្មាធិការជាតិ និងអង្គពិធីទាំងមូល ខ្ញុំសូមគោរពអនុញ្ញាតធ្វើសេចក្តីរាយការណ៍ដោយសង្ខេបជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** អំពីដំណើរការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ដូចខាងក្រោម៖

ថ្ងៃនេះ គឺជាការប្រារព្ធរៀបចំវេទិកាអន្តរសាសនាថ្នាក់ជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សលើកទី៦ ដោយគិតចាប់ពីឆ្នាំ២០១៧មក កម្មវិធីនេះ ត្រូវបានប្រព្រឹត្តទៅយ៉ាងអធិកអធម និងបានបញ្ជាក់អំពីភាពសុខដុមរមណីយនៃសាសនាទាំងឡាយនៅកម្ពុជា ។ ក៏ប៉ុន្តែនៅឆ្នាំ២០២០-២០២១ គឺជាពេលវេលាដ៏លំបាកដែលថ្នាក់ដឹកនាំ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ គ្រូពេទ្យ អាជ្ញាធរ ក៏ដូចជា

ប្រជាពលរដ្ឋ បានប្រឹងប្រែងតស៊ូ ទប់ទល់នឹងបញ្ហាប្រឈម បង្កឡើងដោយការរាតត្បាតនៃជម្ងឺកូវីដ-១៩ ដោយពេលនោះគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ពុំបានរៀបចំកម្មវិធីជួបជុំទ្រង់ទ្រាយធំដូចនេះឡើយ តែបានរៀបចំជាបទយកការណ៍ និងការផ្សព្វផ្សាយជាទម្រង់វីដេអូ និងទទួលបានការអញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី ដើម្បីថ្លែងសុន្ទរកថាបើកកម្មវិធី និងផ្សព្វផ្សាយ ទូទាំងប្រទេស និងទូទាំងសកលលោកផង ។

ក្នុងកម្មវិធីអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស ប្រាំមួយលើកកន្លងមកនេះ មានការចូលរួមពីនិកាយនៃ**សាសនាធំៗបី** គឺ **ព្រះពុទ្ធសាសនា ឥស្លាមសាសនា និង គ្រិស្តសាសនា** ប្រកបដោយឆន្ទៈ និងបានព្រមព្រៀងគ្នាស្វែងរកវិធីសាស្ត្រ ដើម្បីអប់រំ ទូន្មាន ប្រៀនប្រដៅមនុស្សទាំងឡាយ ឲ្យប្រព្រឹត្តនូវអំពើល្អ ចេះស្រឡាញ់ខ្លួនឯង ស្រឡាញ់គ្រួសារ ស្រឡាញ់មនុស្សជាតិ និងចេះជួយការពារគ្នាទៅវិញទៅមក មិនសាងបាបលើអ្នកដទៃឲ្យរងទុក្ខដោយសារខ្លួនឡើយ ។

ឆ្នាំនេះ វេទិកាអន្តរសាសនាកម្ពុជាបានលើកយកប្រធានបទរួមមួយគឺ **«សូមកុំយកកម្ពុជា ជាគោលដៅប្រព្រឹត្តអំពើជួញដូរមនុស្ស!»** ដែលជាការអំពាវនាវផង និងប្រឆាំងផង ចំពោះរាល់សកម្មភាពទុច្ចរិតដែលប្រព្រឹត្តក្នុងដែនដី នៃព្រះរាជាណាចក្រកម្ពុជា ទៅលើប្រជាជនកម្ពុជា ក៏ដូចជាជនបរទេស ដែលអំពើដ៏ឃោរឃៅនេះ បានបំផ្លាញទាំងធនធានមនុស្ស ទាំងកិត្តិយស ទាំងភាពសុខដុមរមនារបស់សង្គមជាតិ ។

កន្លងមក មានប្រជាជនកម្ពុជា ជាច្រើនដែលបានធ្វើទេសន្តរប្រវេសន៍ ស្វែងរកការងារធ្វើនៅក្រៅប្រទេស ដោយប្រថុយប្រថាន ក្នុងនោះមួយចំនួនត្រូវបានរងទុក្ខវេទនាក្នុងទម្រង់ជាការងារបង្ខំ និងលំបាកយ៉ាប់យ៉ឺន មិនបានទទួលកម្រៃប្រាក់

ឈ្នួលតាមសន្យា ហើយក៏ត្រូវបានគេជួញដូរ កេងប្រវ័ញ្ច និងប្រើប្រាស់កម្លាំងពលកម្ម ដោយបង្ខំ ។ គួរឲ្យសង្វេគជាងនេះទៅទៀត មានខ្លះបាត់ដំណឹងមិនបានវិលត្រឡប់ មកជួបក្រុមគ្រួសារ ខ្លះធ្លាក់ខ្លួនពិការ ខ្លះបាត់បង់កាយសម្បទា ឬបញ្ញាស្មារតី និង កំពុងស្ថិតនៅក្នុងស្ថានភាពជាជនទេសន្តរប្រវេសន៍ ដែលគ្មានឯកសារច្បាប់ត្រឹមត្រូវ ធ្វើឲ្យជនល្មើសងាយស្រួលធ្វើសកម្មភាពប្រើប្រាស់ដោយកេងប្រវ័ញ្ច និងរំលោភបំពាន ហើយមានខ្លះទៀតត្រូវបានរងគ្រោះរហូតដល់ស្លាប់បាត់បង់ជីវិតទៀតផង ។

រាជរដ្ឋាភិបាលកម្ពុជា បាន និងកំពុងដោះស្រាយករណីជាច្រើន និងនៅតែ បន្តដោះស្រាយជាបន្តបន្ទាប់ ហើយក៏បានបង្ការទប់ស្កាត់ និងបង្ក្រាបសកម្មភាព បទល្មើសជាច្រើនដែលនាំដល់ការជួញដូរមនុស្ស រួមទាំងការនាំមនុស្សឆ្លងដែន ដោយខុសច្បាប់ ដើម្បីសង្គ្រោះប្រជាពលរដ្ឋពីភាពជាជនរងគ្រោះ និងបញ្ជូនជន ប្រព្រឹត្តបទល្មើសទៅផ្តន្ទាទោសតាមច្បាប់ជាធរមាន។ សកម្មភាពបង្ក្រាបនេះ បានកើនឡើងទ្វេដង ក្នុងឆ្នាំ២០២១ បើប្រៀបធៀបនឹងឆ្នាំ២០២០ បើទោះបីជា ក្នុងអំឡុងពេលនោះ កម្ពុជាកំពុងស្ថិតក្នុងការញាំញីដោយការរាតត្បាត នៃជម្ងឺ កូវីដ-១៩ក៏ដោយ ។

ក្នុងពេលជាមួយគ្នានេះ ពលករកម្ពុជា ដែលត្រូវបានបញ្ជូនត្រឡប់មកកម្ពុជាវិញ ដោយអាជ្ញាធរបរទេស ឬវិលត្រឡប់ដោយខ្លួនឯងក្នុងអំឡុងពេល នៃការប្រកាស បិទព្រំដែន ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃកូវីដ-១៩ ក៏ត្រូវបានកើនចំនួន យ៉ាងគំហុក ។ មកដល់បច្ចុប្បន្ននេះ មានប្រជាពលរដ្ឋកម្ពុជា ប្រមាណ៣០ម៉ឺននាក់ បានវិលត្រឡប់ ឬត្រូវបានបញ្ជូនត្រឡប់មកកម្ពុជាវិញ ដោយអាជ្ញាធរបរទេស ហើយត្រូវទទួលបាននូវការគាំពារយ៉ាងយកចិត្តទុកដាក់ពីសមត្ថកិច្ច និងអាជ្ញាធរ-មូលដ្ឋានគ្រប់លំដាប់ថ្នាក់។ មកដល់ដើមឆ្នាំ២០២២ សភាពការណ៍កូវីដ-១៩ នៅ

កម្ពុជាបានធូរស្រាល ដែលជាហេតុនាំឲ្យរាជរដ្ឋាភិបាលត្រូវចាប់ផ្តើមសកម្មភាពសេដ្ឋកិច្ចឡើងវិញ នៅទូទាំងប្រទេសក្នុងគន្លងប្រក្រតីភាពថ្មី ។

ទន្ទឹមនឹងស្ថានភាពដ៏ប្រសើរនេះ បែរជាកើតមានរឿងមួយដែលគួរឲ្យសោកស្តាយនោះគឺ ការលេចចេញនូវបទល្មើសថ្មីមួយទៀត លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា គឺបទល្មើសឆបោកតាមប្រព័ន្ធទូរគមនាគមន៍យ៉ាងគគ្រឹកគគ្រេង ព្រមជាមួយនឹងការប្រើប្រាស់មនុស្សដោយបង្ខំ កេងប្រវ័ញ្ចប្រាក់ឈ្នួល បិទសិទ្ធិសេរីភាព និងប្រើប្រាស់ជនរងគ្រោះជាឧបករណ៍សម្រាប់បោកប្រាស់អ្នកដទៃទៀត ធ្វើឲ្យកម្ពុជារងផលប៉ះពាល់ជាអវិជ្ជមាន ដល់កេរ្តិ៍ឈ្មោះរបស់ព្រះរាជាណាចក្រកម្ពុជា លើឆាកអន្តរជាតិ ។ សហរដ្ឋអាមេរិក បានចាត់កម្ពុជា ក្នុងលំដាប់ថ្នាក់លេខ ៣ រួមជាមួយបណ្តាប្រទេស៤ទៀត ក្នុងសហគមន៍អាស៊ាន មាន វៀតណាម ម៉ាឡេស៊ី ប្រ៊ុយណេ និងប្រទេសមីយ៉ាន់ម៉ា ដែលមានន័យថាជាបណ្តាប្រទេសដែលមានកិច្ចខិតខំប្រឹងប្រែងដ៏តិចតួចក្នុងសកម្មភាពប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ។ ជាក់ស្តែងបទល្មើសនេះ គឺជាទម្រង់ឧក្រិដ្ឋកម្មឆ្លងដែន ដែលមានបណ្តាញចាត់តាំងនៅរាយប៉ាយតាម បណ្តាប្រទេសនានាក្នុង និងក្រៅតំបន់ និងត្រូវបានក្រុមឧក្រិដ្ឋជនលួចលាក់ធ្វើសកម្មភាពយ៉ាងសម្ងាត់ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងរូបភាពល្បែងអនឡាញ និងប្រើប្រាស់ឧបាយកលឆបោកអ្នកវិនិយោគ អូសទាញអ្នកដែលចាញ់កលល្បិចខ្លួន ដើម្បីកេងប្រវ័ញ្ចធនធានយ៉ាងអាថ៌កំបាំង ព្រមទាំងបង្ខំមនុស្សឲ្យធ្វើការលើសម៉ោងកំណត់ ក្នុងកន្លែងបិទជិត មិនផ្តល់សេរីភាពដើរហើរ រហូតដល់មានការឃុំឃាំងធ្វើទារុណកម្ម ដើម្បីជម្រិតទារប្រាក់ពីក្រុមគ្រួសារជនរងគ្រោះជាដើម។ ជនល្មើសមួយចំនួនមានទាំងអាវុធប្រើប្រាស់ខុសច្បាប់បន្ថែមទៀតផង ដែលសកម្មភាពនេះ បើមិនបង្ការទប់ស្កាត់ទេ អាចជាការគម្រាមកំហែងដល់សន្តិសុខជាតិយ៉ាងធ្ងន់ធ្ងរ នៅពេលអនាគត។

ក្នុងស្ថានភាពដ៏អាក្រក់នេះ រាជរដ្ឋាភិបាលកម្ពុជា ដែលមានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាសេនាធិការ បានដាក់ចេញផែនការលេខ ១៤៣/២២ ផ.ក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ ជាផែនការប្រតិបត្តិការបង្កើនការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ ការជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ដើម្បីធ្វើឲ្យសម្រេចគោលការណ៍សំខាន់បួនយ៉ាងគឺ (១).សង្គ្រោះជនរងគ្រោះឲ្យបានទាន់ពេលវេលា (២).ស៊ើបអង្កេតរកជនប្រព្រឹត្តបទល្មើស និងបក្សពួក និងស្រាវជ្រាវរកមេខ្លោង ដើម្បីផ្តន្ទាទោសតាមច្បាប់ដោយគ្មានការលើកលែង (៣).ត្រួតពិនិត្យ ប្រមូលភស្តុតាង ដើម្បីបិទអាជីវកម្មខុសច្បាប់ ជាពិសេសល្បែងស៊ីសងនិងល្បែងតាមប្រព័ន្ធអេឡិចត្រូនិកដែលខុសច្បាប់ (៤).បើរកឃើញថាជាករណីជួញដូរមនុស្ស សមត្ថកិច្ចត្រូវពន្លាតការស៊ើបអង្កេតរកសកម្មភាពបទល្មើសសម្អាតប្រាក់ថែមទៀត ដើម្បីបោសសម្អាតបទល្មើសឧក្រិដ្ឋដែលពាក់ព័ន្ធ ។

បន្ថែមលើនេះគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានប្រកាសចេញនូវសេចក្តីអំពាវនាវ ដល់ស្ថានតំណាងបេសកកម្មការទូតនានា និងសាធារណជន ដែលបានដឹង និងស្គាល់ទីតាំងដែលប្រព្រឹត្តបទល្មើស ឲ្យជួយសហការក្នុងការផ្តល់ព័ត៌មាន មកក្រុមការងារប្រតិបត្តិការ តាមប្រព័ន្ធហ្វេសប៊ុកផ្លូវការរបស់ខ្ញុំ ឬរបស់ក្រសួងមហាផ្ទៃ ឬរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ និងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក៏ដូចជាតាមប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍របស់អគ្គស្នងការដ្ឋាននគរបាលជាតិ។

ដើម្បីធ្វើឲ្យផែនការប្រតិបត្តិការនេះទទួលបានជោគជ័យ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស បានបង្កើតក្រុមការងារចំពោះកិច្ច ដើម្បីធ្វើជាយន្តការអនុវត្តឲ្យប្រកបដោយប្រសិទ្ធភាព។

-សម្ដេចតេជោ នាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់!

-គណៈអធិបតី ភ្ញៀវកិត្តិយស សមាជិក សមាជិកា នៃអង្គពិធីនាំងមូល ជាទីមេត្រី!

គិតចាប់ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ រហូតមកដល់បច្ចុប្បន្ន ចំនួនបណ្ដឹងដែលបានទទួល តាមប្រព័ន្ធហ្វេសប៊ុក និងប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ មានប្រមាណ ៣៦៨ករណី ក្នុងនោះ ជនល្មើសបានធ្វើសកម្មភាព ក្នុងខេត្តព្រះសីហនុច្រើនជាងគេ គឺរហូតដល់ ២៤៩ករណី។ ក្រុមប្រតិបត្តិការ បានធ្វើសកម្មភាពរុករកជនល្មើសនៅតាមបណ្ដាទីតាំងសង្ស័យ តាមសេចក្ដីរាយកាណ៍ បានសង្គ្រោះជនរងគ្រោះ ចំនួន ៣៦១នាក់ ក្នុងនោះ រងគ្រោះដោយអំពើជួញដូរ ០៩ករណី មានមនុស្ស ៥៤នាក់ មាន ៦សញ្ជាតិ។ សមត្ថកិច្ចក៏បានធ្វើការឃាត់ខ្លួនជនសង្ស័យប្រព្រឹត្តបទល្មើស ៤១នាក់ មាន ៣សញ្ជាតិ បញ្ជូនទៅតុលាការ រឹបអូសវត្ថុតាង និងបិទទីតាំង ដើម្បីធ្វើការស៊ើបអង្កេតប្រមូលភស្តុតាងបន្ថែមទៀត។ ក្រៅពីនេះនៅមានជនរងគ្រោះរាប់រយនាក់ទៀត ដែលត្រូវបានសមត្ថកិច្ចយើងរកឃើញ ដែលទោះបីជាអ្នកទាំងនោះ មិនមែនជាជនរងគ្រោះដោយអំពើជួញដូរក៏ដោយ ក៏ត្រូវបានសមត្ថកិច្ចយើង រំដោះចេញពីទីតាំងដ៏គ្រោះថ្នាក់ នាំទៅកាន់ទីតាំងសុវត្ថិភាព ក្រោមកិច្ចសហការ និងសម្របសម្រួលពីបណ្ដាស្ថានទូតនៃប្រទេសសាមី ដែលមានការពាក់ព័ន្ធដើម្បីបានវិលត្រឡប់ទៅកាន់មាតុភូមិ និងជួបជុំក្រុមគ្រួសារវិញ ដោយសុវត្ថិភាព។ នៅមានបងប្អូនកូនក្មួយជាច្រើនទៀត ដែលនៅតែមិនព្រមលះបង់ជំនឿលើឧក្រិដ្ឋជន ហើយចង់បន្តធ្វើការងារបម្រើឧក្រិដ្ឋជន ទាំងមិនដឹងថាខ្លួនកំពុងស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ឡើយ។ ជនរងគ្រោះទាំងនោះភាគច្រើនជាយុវវ័យដែលចេះជំនាញបច្ចេកវិទ្យាព័ត៌មានយ៉ាងស្ទាត់ជំនាញ តែនៅតែចាញ់បោកឧក្រិដ្ឋជន ឲ្យយកចំណេះដឹងខ្លួនឯង ទៅបម្រើឲ្យឧក្រិដ្ឋជន ដែលបំផ្លាញខ្លួនឯងផង និងអ្នកដទៃផង។ មួយចំនួនទៀត មិនមានការពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សទេ

តែជាករណីលួចលាក់ឆ្លងដែនចូលមកកម្ពុជាដោយខុសច្បាប់ និងសម្ងំលាក់ខ្លួនធ្វើការងារដោយគ្មានការអនុញ្ញាត ។

ខ្ញុំសូមយកឱកាសនេះ ដើម្បីសម្តែងនូវអំណរគុណចំពោះអង្គទូតនៃប្រទេសពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល បណ្តាញសារព័ត៌មានទាំងអស់ ដែលបានជួយផ្តល់ព័ត៌មានពិតពីអំពើសកម្មភាពជនល្មើស និងជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងសកម្មភាពទុច្ចរិតទាំងឡាយ ដែលបណ្តាញឧក្រិដ្ឋជនបានលបលួចប្រព្រឹត្តក្រោមស្លាកអាជីវកម្មផ្សេងៗនៅកម្ពុជា ដើម្បីបង្កលក្ខណៈឲ្យកម្លាំងសមត្ថកិច្ចអាចឈានទៅបង្ក្រាប និងសង្គ្រោះជនរងគ្រោះបានទាន់ពេលវេលា។ នេះជាស្មារតីសហការដ៏មានសារសំខាន់ ក្នុងគោលដៅលុបបំបាត់អំពើជួញដូរមនុស្សនៅកម្ពុជា ដែលមិនមែនជាការផ្សព្វផ្សាយ ដោយគ្មានការទទួលខុសត្រូវ ដើម្បីបន្ទុះបង្អាប់កម្ពុជានោះទេ ។ ឧក្រិដ្ឋជនមានកលល្បិចបត់បែន ប្រើគ្រប់មធ្យោបាយ និងព្យាយាមរកឱកាស ដើម្បីកេងប្រវ័ញ្ចតាមគ្រប់រូបភាព លើជនរងគ្រោះគ្រប់វ័យ គ្រប់ភេទ គ្រប់សញ្ជាតិ ឲ្យតែគេអាចធ្វើការបោកបញ្ឆោត អូសទាញ និងប្រើប្រាស់បាន។ នេះជាមូលហេតុ ដែលព្រះរាជាណាចក្រកម្ពុជា សូមអំពាវនាវដល់បណ្តាប្រទេសទាំងអស់ ដែលមានការពាក់ព័ន្ធ សូមសហការគ្នា ដើម្បីលុបបំបាត់អំពើជួញដូរមនុស្ស ដែលចាប់ផ្តើមពីការផ្សព្វផ្សាយអប់រំ បង្ការទប់ស្កាត់ ការស៊ើបអង្កេតស្រាវជ្រាវ បង្ក្រាប ការការពារជនរងគ្រោះ ការផ្តន្ទាទោសជនល្មើសឲ្យបានម៉ឺងម៉ាត់ទាំងអស់គ្នា និងទទួលស្គាល់ថានេះជាឧក្រិដ្ឋកម្មឆ្លងដែន ដែលមានបណ្តាញចាត់តាំងជាខ្សែសង្វាក់ ពីប្រទេសមួយទៅប្រទេសមួយ ។

មុននឹងឈានដល់ការរៀបចំកម្មវិធីនាថ្ងៃនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានធ្វើការស្ទាបស្ទង់មតិលើប្រជាពលរដ្ឋចំនួន

១.១៥៣នាក់ ក្នុងនោះមានស្ត្រី ចំនួន ៣៤១នាក់ នៅ១៣រាជធានីខេត្ត និងបាន ផ្តល់យោបល់ និងយល់ឃើញដូចខាងក្រោម ៖

មូលហេតុដែលនាំឲ្យមានអំពើរជួញដូរមនុស្ស មានជាអាទិ៍៖

១.បន្ទុកគ្រួសារ និងបំណុល

២.ខ្វះការយកចិត្តទុកដាក់ពីគ្រួសារ និងសង្គម

៣.ខ្វះការសិក្សាអប់រំ

៤.ខ្វះការទទួលព័ត៌មានគ្រប់គ្រាន់ ដែលផ្សព្វផ្សាយដោយរាជរដ្ឋាភិបាល និង អង្គការសង្គមស៊ីវិលនានា

៥.ការចាញ់ល្បែងស៊ីសង ការសេពគ្រឿងញៀន គ្រឿងស្រវឹង ។

ទាំងនេះគឺជាកង្វល់របស់ប្រជាពលរដ្ឋ ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ បន្ថែមទៀត លើការអប់រំផ្សព្វផ្សាយ អំពីកលល្បិចជនល្មើស ការពង្រឹងសុវត្ថិភាព ក្នុងសហគមន៍ ការបង្កើនឱកាសការងារ និងមុខរបរខ្នាតតូច និងមធ្យម សម្រាប់ ប្រជាពលរដ្ឋ ពង្រឹងការដាំដុះ ការចិញ្ចឹមសត្វ សម្រាប់សុវត្ថិភាពស្បៀង និងត្រូវ បង្កើនការបង្ក្រាប និងពង្រឹងការអនុវត្តច្បាប់ ឲ្យបានម៉ឺងម៉ាត់លើការជួញដូរ ចែកចាយ ប្រើប្រាស់គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ដែលនាំឲ្យមានអំពើ ហិង្សា និងការលួចឆក់ប្លន់ និងអសន្តិសុខដល់សហគមន៍ និងត្រូវការកាត់បន្ថយ ការប្រើប្រាស់គ្រឿងស្រវឹង ។ បង្កើនការយកចិត្តទុកដាក់បន្ថែមទៀត ក្នុងការផ្តល់ សេវាជូនប្រជាពលរដ្ឋ ឲ្យបានទាន់ពេលវេលា ដើម្បីផ្តល់ភាពកក់ក្តៅ និងការជឿ ជាក់លើអាជ្ញាធរ និងសមត្ថកិច្ច ដែលជាមន្ត្រីរបស់រាជរដ្ឋាភិបាល ។

ទន្ទឹមនឹងនោះ គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បាននិងកំពុងចាត់វិធានការ យ៉ាងស្រួចស្រាល់ ក្នុងការធ្វើប្រតិបត្តិការរុករកដើម្បី សង្គ្រោះជនរងគ្រោះ ព្រមទាំងបង្ក្រាបបទល្មើស និងចាប់ជនប្រព្រឹត្តបទល្មើស ដើម្បីធ្វើការផ្តន្ទាទោស និងចាត់វិធានការតាមផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ ពល់ករណី បទល្មើស ដែលបានរកឃើញ ដោយមិនមានការលើកលែង ។ ក្រសួងមហាផ្ទៃ

ក្រសួងយុត្តិធម៌ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងពាក់ព័ន្ធមួយចំនួនទៀត បាន និងកំពុងធ្វើការងារយ៉ាងសកម្ម ដើម្បីធានាថាកិច្ចប្រតិបត្តិការ ដែលកំពុងធ្វើនេះនឹងបានទទួលជោគជ័យ។

លើសពីនេះទៅទៀត ការចូលរួមពីវិស័យសាសនា គឺជាយន្តការនៃការផ្សព្វផ្សាយដ៏មានសក្តានុពល និងប្រសិទ្ធភាព ក្នុងការជួយផ្សព្វផ្សាយ អប់រំដល់ប្រជាពលរដ្ឋឲ្យបានយល់ច្បាស់ពីបំណងប្រាថ្នា និងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពីគុណវិបត្តិនៃការប្រព្រឹត្តអំពើហិង្សា អមនុស្សធម៌ អំពើជួញដូរមនុស្ស និងបទល្មើសផ្សេងៗទៀត ដល់ប្រជាជន តាមភូមិ ឃុំ វត្តអារាម ព្រះវិហារ សាលារៀន មន្ទីរពេទ្យ ទីផ្សារ និងកន្លែងប្រមូលផ្តុំនានា ។ល។

**ជាទីបញ្ចប់នេះ** ខ្ញុំព្រះករុណាខ្ញុំ សូមលំឱនកាយថ្វាយព្រះសព្ទសាធុកាពរចំពោះសម្តេចព្រះសង្ឃរាជទាំងពីរគណៈ ប្រគេនព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងជូនចំពោះ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម លោកជំទាវសមាជិកព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ឯកឧត្តម លោកជំទាវ ជាតំណាងអង្គទូត និងស្ថានតំណាងនានាប្រចាំនៅកម្ពុជា ថ្នាក់ដឹកនាំគ្រប់និកាយសាសនា ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិកសមាជិកានៃកម្មវិធីទាំងមូល សូមប្រកបដោយ ពរទាំងឡាយពីព្រះជាម្ចាស់ និងពុទ្ធពរទាំងបួនប្រការ គឺ**អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ** ៕

**សូមអរព្រះគុណ សូមអរគុណ!**